# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

## ការិយាល័យផ្នែក កម្មវិធីសិក្សា ការបង្ហាត់បង្រៀន និង ការវាយតម្លៃ


440 N. Broad Street
2nd Floor, Suite 251 Portal C
Philadelphia, PA 19130
(២១៥)-៤០០-៤៨២០-៤២១០


ជូនចំពោះ មាតាបិតា និងអាណាព្យាបាល របស់សិស្សានុសិស្សថ្នាក់ទី ៩ ១០ និង ១១៖

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ានឹងចាត់ចែងការប្រឡងបឋម SAT/គុណភាពចំណេះដឹងនៃការប្រឡងទូទាំងប្រទេស (National Merit Qualifying Test) (**PSAT/NMSQT**) ដល់សិស្សានុសិស្សថ្នាក់ទីប្រាំបួន និងថ្នាក់ទីដប់ ទាំងអស់ **<u>នៅថ្ងៃពុធ ទី១៤ ខែតុលា ឆ្នាំ ២០១៥ នៅវិទ្យាល័យរបស់ពួកគេ ដោយមិនយកតម្លៃបន្ថែមពីមាតាបិតា ឬ ពីសិស្ស។</u>** ការប្រឡងនេះនឹងផ្តល់ឲ្យកូនរបស់លោកអ្នកនូវឱកាសចាប់ផ្តើមធ្វើដំណើរទៅកាន់មហាវិទ្យាល័យ។ ការប្រឡង PSAT ផ្តល់ការហ្វឹកហាត់សម្រាប់ការប្រឡង SAT និងផ្តល់ឲ្យសិស្សនូវឱកាសត្រៀមខ្លួនជាស្រេចសម្រាប់ការប្រឡងចូលមហាវិទ្យាល័យ។ គេនឹងផ្តល់លទ្ធផលទៅឲ្យសិស្សនៅដើមរដូវរងា ដែលមានទាំងសំណួមពរសម្រាប់ជាការកែលម្អ។

ដោយសារការប្រឡង PSAT/NMSQT កូនលោកអ្នកនឹងមានឱកាសដឹងអំពីព័ត៌មាននៃការប្រឡង SAT។ ឯកសារត្រៀម នឹងធ្វើឲ្យមានភាពងាយស្រួលដល់សិស្សក្នុងការរកព័ត៌មានផ្សេងៗដែលអាចជួយត្រៀមខ្លួនសម្រាប់អនាគតរបស់ពួកគេ។ ជំនួយរួមមាន ប៉ុន្តែគ្មានកំណត់ ដូចជា៖

- ការត្រៀមខ្លួនប្រឡង SAT តាមរយៈ Khan Academy ដោយឥតគិតថ្លៃ។
- ការបង្ហាត់បង្រៀនផ្ទាល់តាមអ៊ិនធ័រណិត និងអាចរកព័ត៌មានអំពី មហាវិទ្យាល័យ និង អាជីព ទៅតាមចំណង់ចំណូលចិត្ត។
- អាចចូលមើលក្នុងវ៉ិបសៃ MyRoad ដែលជាវ៉ិបសៃអាចទាក់ទងឆ្លើយឆ្លងគ្នារៀបគម្រោងសម្រាប់ មហាវិទ្យាល័យ និងអាជីព។

ជាការសំខាន់ដែលកូនលោកអ្នកឆក់យកឱកាសដ៏ប្រសើរនេះ ដោយមករៀនឲ្យទាន់ពេលវេលា និងញុំាអាហារពេលព្រឹកដែលជួយឲ្យមានសុខភាពល្អ។ ក្រោយពេលប្រឡងរួច សិស្សានុសិស្សនឹងត្រឡប់ទៅថ្នាក់រៀនរបស់ពួកគេតាមធម្មតាវិញ។ បើសិនជាលោកអ្នកមានសំណួរអ្វីអំពីការប្រឡង PSAT/NMSQT ហើយថាតើគេរៀបចំការប្រឡងនេះរបៀបណានៅសាលារបស់កូនលោកអ្នក សូមទាក់ទងមកអ្នកផ្តល់ឱវាទនៅសាលារបស់ពួកគេ។

ដើម្បីជ្រាបព័ត៌មានទូទៅអំពីការប្រឡង សូមមើលវ៉ិបសៃ៖
https://sites.google.com/a/philasd.org/sdppsat.

យើងខ្ញុំសង្ឃឹមថាកូនលោកអ្នក នឹងប្រឡង PSAT នេះ ដើម្បីជាឱកាសឈោងទៅចាប់អនាគតដ៏ភ្លឺស្វាង។ សូមអរគុណចំពោះការបន្តគាំទ្ររបស់លោកអ្នក ដល់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា និងការខិតខំរបស់យើងខ្ញុំ ដើម្បីធ្វើយ៉ាងណាឲ្យសិស្សានុសិស្សរបស់យើង ១០០% បានបញ្ចប់ការសិក្សា ដែលមានការត្រៀមខ្លួនជាស្រេចសម្រាប់ មហាវិទ្យាល័យ និង អាជីព។

ដោយសេចក្តីស្មោះស្ម័គ្រ

Christopher Shaffer
នាយករង
កម្មវិធីសិក្សា ការបង្ហាត់បង្រៀន និង ការវាយតម្លៃ